# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**
**និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**

## របាយការណ៍

## ស្តីពីលទ្ធផលនៃកិច្ចប្រជុំក្រុមការងារបច្ចេកទេសតុលាការគំរូ

ឆ្នាំពីរពាន់ប្រាំពីរ ខែ កក្កដា ថ្ងៃទី ដប់ពីរ វេលាម៉ោងបី នៅសាលប្រជុំរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ មានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសតុលាការគំរូជាលើកទី១ ក្រោមអធិបតីភាពរបស់ឯកឧត្តម **សួង លាងហៃ** នាយករងអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់មកជាមួយ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **សួង លាងហៃ** តាងនាមអោយឯកឧត្តម **ស៊ុយ ម៉ុងលាង** នាយកអង្គភាពគ្រប់គ្រងគម្រោង និងជាប្រធានក្រុមការងារដែលជាប់ទាក់ទងការកិច្ចផ្សេង បានថ្លែងអំណរគុណចំពោះអ្នកចូលរួមទាំងអស់ហើយជាបន្ទាប់ ឯកឧត្តម បានជម្រាបជូនថាគោលបំណងនៃកិច្ចប្រជុំ គឺដើម្បីផ្តល់ឱកាសឱ្យតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ ដែលត្រូវបានចាត់តាំង ឱ្យចូលរួមក្នុងក្រុមការងារបច្ចេកទេសតុលាការគំរូ បានជួបជុំគ្នាជាលើកដំបូងស្វែងយល់ពីភារកិច្ចរបស់ខ្លួន និងត្រៀមចូលរួម ប្រជុំពិភាក្សាតាមរយៈវីដីអូឆ្លើយឆ្លង (Video Conference ) ជាមួយនឹងក្រុម ការងារពីប្រទេសដាណឺម៉ាក ដែលគ្រោង ធ្វើនៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ វេលាម៉ោងបីរសៀល ។

ឯកឧត្តមបានគូសបញ្ជាក់ជូនអង្គប្រជុំ អំពីគោលការណ៍សំខាន់ៗនៃតុលាការគំរូ ហើយក្នុងពេលនោះដែរ ឯកឧត្តម ក៏បានរំលឹកអំពីការប្រជុំថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៧ កន្លងទៅស្តីពីតុលាការគំរូ ដែលបានសម្រេចជ្រើសរើស តុលាការខេត្តក្រុងចំនួនបួនសម្រាប់អនុវត្ត "គម្រោងតុលាការគំរូ" រួមមាន តុលាការក្រុងភ្នំពេញ តុលាការខេត្តកំពង់ចាម តុលាការខេត្តបន្ទាយមានជ័យ និងតុលាការខេត្តកណ្តាល ដែលបាននឹងកំពុងអនុវត្តគម្រោងតុលាការគំរូនេះនៅក្នុងក្រប ខណ្ឌ័នៃជំនួយអូស្ត្រាលី CCJAP ។

ដើម្បីឱ្យអង្គប្រជុំកាន់តែយល់ច្បាស់អំពីខ្លឹមសារនៃតុលាការគំរូ ឯកឧត្តមប្រធានអង្គប្រជុំបានស្នើសុំឯកឧត្តម **ខៀវ សាម៉េត** ប្រធានតុលាការគំរូខេត្តកណ្ដាល ដែលជាសមាជិកក្រុមការងារជាន់ខ្ពស់តុលាការគំរូ និងដែលមានបទពិសោធន៍ច្រើនក្នុងការអនុវត្តគម្រោងតុលាការគំរូ ជួយចូលរួមផ្ដល់ជាមតិយោបល់ដល់អង្គប្រជុំ ។

ឯកឧត្តម **ខៀវ សាម៉េត** បានបញ្ជាក់ជូនថា តុលាការគំរូត្រូវមានលក្ខណៈវិនិច្ឆ័យប្រាំយ៉ាងដូចខាងក្រោម ៖

1- ត្រូវមានអាគារសម្រាប់ធ្វើការ គឺថា បើគ្មានអាគារទេនោះ តុលាការមិនអាចធ្វើការបានទេ

2- មានអាគារហើយអាគារនោះត្រូវមានបំពាក់សម្ភារៈបរិក្ខារ និងមានថវិកាគ្រប់គ្រាន់ សម្រាប់ដំណើរការ ទៀត ដូចជាសម្រាប់ធ្វើដំណើរចុះអង្កេតរឿងក្ដីជាដើម

3- ត្រូវយកចិត្តទុកដាក់រៀបចំរចនាសម្ព័ន្ធរដ្ឋបាលតុលាការឱ្យបានល្អ ជាពិសេសលើការងារគ្រប់គ្រង ចាត់ចែង តាមដាន និងដោះស្រាយរឿងក្ដី

4- ត្រូវមានច្បាប់សម្រាប់អនុវត្តដូចជាក្រមនីតិវិធីព្រហ្មទណ្ឌជាដើម

5- ត្រូវមានធនធានមនុស្សគ្រប់គ្រាន់ និងប្រកបដោយសមត្ថភាពចាំបាច់ ។

ឯកឧត្តមបានមានប្រសាសន៍បន្ថែមទៀតថា ខាងអង្គការក្រៅរដ្ឋាភិបាលបានសុំបន្ថែមមួយចំណុចទៀតទៅលើចំណុច ទាំងប្រាំខាងលើ គឺឯករាជ្យភាពពេញលេញនៃតុលាការ ។

ឯកឧត្តម **ម៉ែន ម៉ុនលា** នាយករងអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក៏បានចូលរួមធ្វើការពន្យល់អំពីតុលាការគំរូនេះដែរ ។ ឯកឧត្តមបានមានប្រសាសន៍ថា គោលដៅរបស់តុលាការ គំរូជាដំបូង គឺរៀបចំក្របខណ្ឌសម្រាប់តុលាការគំរូ តើតុលាការគំរូត្រូវមានលក្ខណៈយ៉ាងណាខ្លះ ? តើត្រូវប្រើយុទ្ធសាស្ត្រ អ្វីខ្លះ? តើត្រូវរៀបចំផែនការអនុវត្តយ៉ាងដូចម្ដេចដែរ ? ការចាំបាច់បំផុតនោះ គឺត្រូវយល់ដឹងអំពីស្ថានការតុលាការគំរូនេះ និងស្វែងយល់អំពីស្ថានភាពជាក់ស្ដែងនៃតុលាការគំរូនីមួយៗ ដើម្បីឈានទៅរៀបចំផែនការសកម្មភាពសម្រាប់អនុវត្ត គម្រោងនាំមួល ។ ជាបន្ទាប់ឯកឧត្តមបានជម្រាបជូនអង្គប្រជុំឱ្យជ្រាបជាដំណឹងអំពីការរៀបចំធ្វើ Video Conference ដែលភ្ជាប់បណ្ដាញពីប្រទេសដាណឺម៉ាកមកកម្ពុជាយើង ហើយដែលនឹងប្រព្រឹត្តទៅនៅពេលដ៏ខ្លីខាងមុខ ។

ចំពោះព័ត៌មានអំពីការប្រជុំឆ្លើយឆ្លងតាមរយៈវីឌីអូ ( Video Conference ) ឯកឧត្តមប្រធានបានសុំឱ្យលោក គង់ ផល្លៈ ធ្វើការជម្រាបជូនអង្គប្រជុំបន្ថែមឱ្យបានច្បាស់លាស់ ។

លោក គង់ ផល្លៈ អនុប្រធានក្រុមគម្រោងកំណែទម្រង់ច្បាប់ បានជម្រាបថា ការធ្វើ Video Conference ដែលគ្រោងធ្វើនៅថ្ងៃទី **១៣** ខែ កក្កដា ឆ្នាំ **២០០៧** ត្រូវបានលើកទៅថ្ងៃទី **២០** ខែកក្កដា ឆ្នាំ **២០០៧** វិញ ដោយរក្សា ពេលវេលាប្រជុំនៅម៉ោងដប់ប្រាំដដែល។ លោកបានជម្រាបផងដែរថា បើលោកបានដំណឹងអ្វីផ្សេងទៀត លោកនឹងជម្រាប ជូនតាមក្រោយ ។ លោកបានបញ្ជាក់ថា នៅក្នុងការប្រជុំ Video Conference នេះ មានការបង្ហាញជូនពីដំណើរការនៃការរៀបចំតុលាការគំរូដោយក្រុមការងារនៅជាណឺម៉ាក នឹងមានការសួរសំណួរក្នុងរយៈពេលសែសិបប្រាំនាទី ។

ឯកឧត្តម **ច័ន្ទ មនោ** នាយកខុទ្ទកាល័យ និងជាទីប្រឹក្សាអមក្រសួងយុត្តិធម៌ បានលើកជាសំណួរទាក់ទងនឹង ការរៀបចំធ្វើតុលាការគំរូនេះ និងផ្តល់ជាយោបល់មួយចំនួនប្រហាក់ប្រហែលនឹងគំនិតដែលឯកឧត្តម **ខៀវ សាម៉េត** បានជម្រាបជូនខាងលើដែរ ។ ដោយឡែកឯកឧត្តមបានសំណូមពរឱ្យក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ចម្លងសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារជាន់ខ្ពស់សម្រាប់គម្រោងតុលាការគំរូជូនក្រសួងយុត្តិធម៌ផង ។

នៅទីបញ្ចប់ឯកឧត្តមប្រធានអង្គប្រជុំបានធ្វើការបូកសរុបលទ្ធផលនៃការប្រជុំដែលបានឯកភាពគ្នាថា នឹង ៖

- បកប្រែបទបង្ហាញរបស់ក្រុមការងារដាណឺម៉ាកជាភាសាខ្មែរ ជូនសមាជិកទាំងអស់សម្រាប់ចូលរួម Video Conference
- ត្រៀម និងអញ្ជើញចូលរួម Video Conference ថ្ងៃទី **២០** ខែ កក្កដា ឆ្នាំ **២០០៧** វេលារសៀល ។ ពេលម៉ោង និងទីកន្លែងច្បាស់លាស់នឹងជម្រាបជូនជាបន្ត ។
- ធ្វើទំនាក់ទំនងជាប្រចាំជាមួយក្រុមការងារដាណឺម៉ាកលើការងារខាងលើ ហើយជូនព័ត៌មានដល់អ្នកចូលរួម ក្នុងករណីទទួលបានព័ត៌មានថ្មី ។

អង្គប្រជុំពិភាក្សាបានបញ្ចប់នៅវេលាម៉ោងបួន និងដប់ប្រាំនាទី ល្ងាចនាថ្ងៃដដែល ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ*

***២០០៧***

**បានឃើញ និងឯកភាព**

**ប្រធានអង្គប្រជុំ** **អ្នកធ្វើរបាយការណ៍**

**សួង លាងហៃ** **សេង វ៉ាន់ដា**

បញ្ជីឈ្មោះសមាសភាពចូលរួមក្នុងកិច្ចប្រជុំពិភាក្សា

នាថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៧

**១- ឯកឧត្តម សួង លាងហៃ នាយករងអង្គភាពគ្រប់គ្រងគម្រោង**

**២- ឯកឧត្តម ប៉ែន ប៊ុនឈា នាយករងអង្គភាពគ្រប់គ្រងគម្រោង**

**៣- ឯកឧត្ដម ចន្ទ័ មនោ នាយកខុទ្ទកាល័យ និងជាទីប្រឹក្សាអមក្រសួងយុត្តិធម៌ និងជាសមាជិក (** TWG )

**៤-ឯកឧត្តម ខៀវ សាម៉េត ប្រធានតុលាការខេត្តកណ្ដាល**

**៥-ឯកឧត្តម ឧត្តមសេនីយ៍ឯក ហេង ហាក់ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ**

**៦-លោក ឈឹម ស៊ីផល ចៅក្រមតុលាការកំពូល និង ជាសមាជិក** ( TWG )

**៧-លោក អ៊ីវ គឹមស្រី ចៅក្រមតុលាការក្រុងភ្នំពេញ**

៨-កញ្ញា សៀក ឆារី មន្ត្រី នៃរាជបណ្ឌិតសភាខជ្ជាជីវៈតុលាការ

៩-លោក កើត វណ្ណារ៉េត ព្រះរាជអាជ្ញាអមតុលាការខេត្តកណ្ដាល

១០- លោក ទៀល សុតិន តំណាង ឯកឧត្តមប្រុក **សារឿន** ក្រសួងមហាផ្ទៃ

១១- Mr. Ben Schultz, Adviser (CCJAP III)

១២- លោក ជ សៀកទេង CCJAP

១៣- លោក បួន សុមុនី

១៤- កញ្ញា ហ៊ួង សុកុល អនុ ប្រធានក្រុមគម្រោងរដ្ឋបាល និងហិរញ្ញវត្ថុ

១៥- លោក តុង ហួត ប្រធានក្រុមគម្រោងកំណែទម្រង់ច្បាប់

១៦- លោក គង់ ផល្លៈ អនុប្រធានក្រុមគម្រោងកំណែទម្រង់ច្បាប់

១៧- លោក ឃ្លោក ដារ៉ា ប្រធានក្រុមគម្រោងសិទ្ធិមនុស្ស និងមជ្ឈត្តកម្ម

១៨- លោក កួយ សៅ អនុប្រធានក្រុមគម្រោងសិទ្ធិមនុស្ស និងមជ្ឈត្តកម្ម

១៩- លោក លោក ហួរ ត័ត្រា មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ

២០- លោក សួន វីរៈ មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ

២១- លោកស្រី យិន កក្កដា មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ

២២- លោកស្រី សេង រ៉ាន់ដា មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ

២៣- កញ្ញា ផាន ពិសីនលក្ខណ៍ មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ